វេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ
ភ្នំពេញ ថ្ងៃទី៥-៧ ខែវិច្ឆិកា ឆ្នាំ២០១៣

# សុន្ទរកថាស្វាគមន៍
# ដោយតំណាងពីក្រសួងផែនការ

ថ្ងៃទី២៖ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣
សណ្ឋាគារសូហ្វីតែល ភោគីតត្រា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

សូមគោរពឯកឧត្តមលោកលោកស្រីភ្ញៀវជាតិនិងអន្តរជាតិ!

១. ខ្ញុំមានកិត្តិយសបំផុតដែលបានអញ្ជើញមកថ្លែងសុន្ទរកថាស្វាគមន៍នៅថ្ងៃទី២ នៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ បន្ទាប់ពីពិធីបើកវេទិកានេះជាផ្លូវការកាលពីម្សិលមិញនេះដោយ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

២. ដូចដែលយើងបានឮកាលពីម្សិលមិញស្រាប់ក្នុងសុន្ទរកថាសម្តេចតេជោនាយករដ្ឋមន្ត្រី ដែលខ្ញុំសូមដកស្រង់ខ្លឹមសារដើមទាំងស្រុង "ការប្រែប្រួលអាកាសធាតុលែងជាអ្វីដែលស្ថិតនៅឆ្ងាយពីយើងទៀតហើយ។ ការប្រែប្រួលអាកាសធាតុកំពុងបង្កឥទ្ធិពលមកលើយើងទាំងអស់គ្នាក្នុងពេលបច្ចុប្បន្ន ..."។ ប្រទេសយើងបន្តប្រឈមការលំបាកចំបងៗបណ្តាលពីហានិភ័យដែលបង្កដោយការប្រែប្រួលអាកាសធាតុ ហើយជាការគួរឱ្យស្តាយផលប៉ះពាល់ខ្លាំងនឹងកើតមានមកលើសហគមន៍ក្រីក្របំផុត ដែលងាយរងគ្រោះបំផុត ជាពិសេសសហគមន៍ជនបទ និងតំបន់ដាច់ស្រយាល។ សម្តេចនាយករដ្ឋមន្ត្រីបានរំលឹកអំពីទឹកជំនន់កន្លងទៅថ្មីៗនេះនៅទូទាំងប្រទេស។ យោងតាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ខេត្តចំនួន ២០ បានរងឥទ្ធិពលពីទឹកជំនន់នេះដោយមានប្រជាជនជិត ២លាននាក់ រងការប៉ះពាល់ដោយផ្ទាល់។ ជំនន់នេះបានធ្វើឲ្យមនុស្សច្រើនជាង ១៥០នាក់បាត់បង់ជីវិត និងការខូចខាតធ្ងន់ធ្ងរចំពោះវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ ស្ពាន និងទំនប់។ បញ្ហានេះបានបង្កឲ្យមានការខូចខាតធំធេងចំពោះរបរចិញ្ចឹមជីវិតរបស់ប្រជាជនកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍជាតិ។

៣. សម្តេចតេជោបានរម្លឹកនៅក្នុងសុន្ទរកថាកាលពីម្សិលម៉ិញថា *"វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមានការពាក់ព័ន្ធជិតស្និទ្ធជាមួយគោលដៅអភិវឌ្ឍន៍ សេដ្ឋកិច្ចនិងសង្គមរបស់យើង"* និង *"មិនមែនជាអ្វីមួយដែលអាចអនុវត្តជាសកម្មភាពបន្ទាប់បន្សំដែលគ្រាន់តែជាការបន្ថែមនោះឡើយ។ វាត្រូវតែរួមបញ្ចូលយ៉ាងជិតស្និទ្ធតាមវិធីដែលអាចគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍ និងការវិនិយោគដែលមានស្រាប់របស់យើង។"* ដូច្នេះយើងត្រូវការឲ្យមានផែនការសមាហរណកម្មកម្រិតខ្ពស់ជាងមុន សម្រាប់ការអភិវឌ្ឍរបស់យើង ដោយផ្អែកលើចក្ខុវិស័យអំពីអាកាសធាតុ។ ជាពិសេស យើងត្រូវប្រឹងប្រែងឈានទៅប្រើប្រាស់ការប្រែប្រួលអាកាសធាតុជាលក្ខណៈវិនិច្ឆ័យ សម្រាប់ជ្រើសរើសយករាល់ការវិនិយោគ និងដំណើរការកសាងផែនការ ដូចជាយេនឌ័រដូច្នោះដែរ។

៤. ប្រសិនបើយើងសង្កេតមើលគោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់យើង ការគិតគូរអំពីការប្រែប្រួលអាកាសធាតុគឺជាលក្ខខណ្ឌមួយ ដើម្បីធានាឲ្យមានជោគជ័យ។ ផ្អែកលើកំណើនសេដ្ឋកិច្ចនៅក្នុងទស្សវត្សរ៍កន្លងទៅ កម្ពុជាទំនងនឹងសម្រេចបានឋានៈជាប្រទេសដែលមានប្រាក់ចំណូលកម្រិតកណ្តាល។ ដូចគ្នានេះដែរ កម្ពុជាកំពុងស្ថិតក្នុងស្ថានភាពល្អ ក្នុងការសម្រេចចំណុចដៅសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដូចជាកាត់បន្ថយភាពក្រីក្រពាក់កណ្តាល ការថែទាំសុខភាពមាតា និងការអប់រំជាសកល។ រាជរដ្ឋាភិបាលកម្ពុជានៅតែប្តេជ្ញាមោះមុតបន្តអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណថ្មីដំណាក់កាលទី៣។ ទោះជាយ៉ាងណាក៏ដោយ កំណើនដែលសម្រេចបានកន្លងមកអាចនឹងបាត់បង់ទៅវិញដោយងាយ ដោយសារតែការប្រែប្រួលអាកាសធាតុ ហើយកិច្ចប្រឹងប្រែងទៅអនាគតអាចជួបការលំបាក លើកលែងតែបានបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ទៅក្នុងដំណើរការកសាងផែនការរបស់យើង។

៥. នៅក្នុងការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍របស់ជាតិ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តជំហានសំខាន់ៗមួយចំនួនរួចមកហើយ។ ដូចដែលសម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ពីម្សិលមិញ *"ការប្រែប្រួលអាកាសធាតុបានក្លាយជាផ្នែកសំខាន់មួយនៃផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់យើង ហើយឥឡូវនេះ បានក្លាយជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ហើយវានឹងក្លាយជាបញ្ហាអន្តរវិស័យផ្លូវការនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមថ្មី ឆ្នាំ២០១៤-២០១៨ របស់ជាតិយើង។ ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ក៏ជាសមាធាតុគន្លឹះមួយនៃគោលនយោបាយ និងផែនការសកម្មភាពអភិវឌ្ឍន៍បៃតងរបស់យើងផងដែរ។"*

៦. ក្រសួងផែនការនឹងបន្តធានាឲ្យមានការដាក់បញ្ចូលសូចនាករពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងក្របខ័ណ្ឌពិនិត្យតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដោយសហការជាមួយក្រសួងបរិស្ថាន យើងនឹងផ្តល់ការគាំទ្រដល់ក្រសួងពាក់ព័ន្ធ ដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងឯកសារធាតុចូលរបស់ក្រសួងទាំងនោះ សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ នៅកម្រិតវិស័យ ថ្ងៃនេះយើងនឹងមានការពិភាក្សាអំពីការងារដែលក្រសួងពាក់ព័ន្ធចំនួនដប់បានអនុវត្ត ដើម្បីបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុរបស់ខ្លួន ដែលជាការបង្ហាញពីកិច្ចប្រឹងប្រែងអនុវត្ត ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងដំណើរការកសាងផែនការជាប្រក្រតីរបស់ខ្លួន និងបញ្ចៀសការចាត់ទុកការប្រែប្រួលអាកាសធាតុថាជាផ្នែកមួយនៅដាច់តែឯង។ ការងារនេះជម្រុញឱ្យមានវិធីសាស្ត្រហ្មត់ចត់ ដោយផ្អែកលើសេណារីយ៉ូហិរញ្ញប្បទានប្រាកដនិយម ដើម្បីចៀសវាងការបង្កើត "តារាងសកម្មភាពដែលគ្រាន់តែជាការចង់បាន" ប៉ុន្តែត្រូវដាក់ចុះនូវកម្មវិធីជាក់លាក់ មានភាពស៊ីសង្វាក់គ្នា និងប្រាកដនិយម។

៧. ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាអង្គវេទិកាទាំងអស់ជាទីមេត្រី ! ទោះជាយ៉ាងណាក៏ដោយ យើងនៅមានកិច្ចការជាច្រើនដែលត្រូវសម្រេចឲ្យបាន។ ការកសាងសមត្ថភាពគឺជាតម្រូវការបន្ទាន់ ដើម្បីអាចរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងដំណើការអភិវឌ្ឍន៍ជាតិ ក៏ដូចជាការបង្កើតក្របខ័ណ្ឌពិនិត្យ

តាមដាន និងវាយតម្លៃ ដែលនឹងជួយតាមដានជោគជ័យនៅក្នុងការវិនិយោគលើការងារប្រែប្រួលអាកាសធាតុ និងផ្តល់ជាមាគ៌ាសម្រាប់ការរៀនសូត្រ សំដៅកែលម្អមូលដ្ឋានចំណេះដឹងរបស់យើង។ យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវសម្រេចឲ្យបាន នៅក្នុងការស្រង់យកមេរៀនដែលទទួលបានពីបទពិសោធន៍ក្នុងគម្រោងសាកល្បងដែលមានស្រាប់ សម្រាប់រួមបញ្ចូលការប្រែប្រួលអាកាសធាតុ ទៅក្នុងការកសាងផែនការនៅថ្នាក់ក្រោមជាតិ និងការបង្កើតគោលការណ៍ណែនាំផ្លូវការ និងគាំទ្រដល់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

៨. ក្នុងពេលដែលការបន្សុំគឺជាអាទិភាពបន្ទាន់បំផុតរបស់យើង ការកសាងផែនការអភិវឌ្ឍន៍ជាតិទាមទារឲ្យសម្លឹងវែងឆ្ងាយទៅអនាគត ដើម្បីប្រែក្លាយសង្គមរបស់យើងទៅរកការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងធន់ទ្រាំនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅអនាគត។ ដូចដែលសម្តេចតេជោនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ "*ការបន្សុំគ្នាឡើងវិញនូវការអភិវឌ្ឍរបស់យើងឆ្ពោះទៅសង្គមមួយដែលមានភាពធន់ និងការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។*" ក្រៅពីការបន្សុំ យើងកំពុងចាត់វិធានការដើម្បីរួមចំណែកនៅក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈដំណោះស្រាយឈ្នះ-ឈ្នះ។ យើងបានខិតខំអភិវឌ្ឍថាមពលកកើតឡើងវិញនៅក្នុងការពង្រីកការផលិតថាមពល និងពង្រីកការផ្តល់សេវាថាមពលដល់ទីជនបទ ប្រជាជននៅតាមទីក្រុងដែលមានកំណើនយ៉ាងឆាប់រហ័ស វិស័យឧស្សាហកម្ម និងសេវាកម្ម។ យើងក៏ជម្រុញឲ្យមានទម្លាប់បង្កើនប្រសិទ្ធិភាពថាមពលផងដែរ ដោយសារវាផ្តល់អត្ថប្រយោជន៍សម្រាប់ធុរកិច្ចនានា ក្នុងការបង្កើនផលចំណេញរបស់ខ្លួន ដោយជាមួយគ្នានោះ រួមចំណែកក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

៩. អនុសាសន៍ដែលយើងនឹងទទួលបានពីការពិភាក្សានាថ្ងៃនេះ ស្របពេលសម្រាប់ដាក់បញ្ចូលទៅក្នុងដំណើការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់រយៈពេល៥ឆ្នាំ ខាងមុខ។ ខ្ញុំសូមលើកទឹកចិត្តដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រើប្រាស់ឱកាសនេះ ដើម្បីស្វែងយល់បន្ថែមទៀតពីការងារប្រែប្រួលអាកាសធាតុ និងសូមចូលរួមយ៉ាងសកម្ម នៅក្នុងដំណើរការពិភាក្សា។ ជាមួយដំណើរការពិស្តារនៃការកសាងផែនការយុទ្ធសាស្ត្រ យើងសង្ឃឹមថា នឹងសម្រេចបានវិធានការឆ្លើយតបរបស់ជាតិក្នុងកម្រិតធំគ្រប់គ្រាន់ បានឆាប់រហ័ស និងចំគោលដៅជាយុទ្ធសាស្ត្រ។

១០. ខ្ញុំសូមឯកឧត្តម លោក លោកស្រី ទទួលបានពុទ្ធពរទាំងបួនប្រការ និងការពិភាក្សាប្រកបដោយផ្លែផ្កា។